ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អត្ថបទស្រាវជ្រាវ

# សមត្ថកិច្ចតុលាការជំនុំជម្រះ

# ក្នុងរឿងក្តីរដ្ឋប្បវេណី

រៀបរៀងដោយៈ គន្ធ គីមហោង

# សមត្ថកិច្ចតុលាការជំនុំជម្រះក្នុងរឿងក្តីរដ្ឋប្បវេណី

សង្គមមនុស្សដែលពោរពេញដោយ ទំនាក់ទំនងរាល់ថ្ងៃ ច្រើនរាប់មិនអស់ក្នុងជីវភាពប្រចាំថ្ងៃ ដូចជាការធ្វើរបរចិញ្ចឹមជីវិត ប្រកបអាជីវកម្មដែលបានបង្កើតបានជាកិច្ចសន្យាលក់ទិញការរៀបអាពាហ៍ពិពាហ៍មាននីតិគ្រួសារ ដើរតួគ្រប់គ្រងការបែងចែកកេរ្តិ៍អាករ សំរាប់កូនចៅដែលចូលគ្រប់គ្រងដោយការបែងចែកសន្តតិកម្មជាដើម ឧទាហរណ៍ទាំងនេះគឺជាទំនាក់ទំនងក្នុងនីតិរដ្ឋប្បវេណី ដែលគ្រប់គ្រងរាល់ទំនាក់ទំនងរវាងបុគ្គល និងបុគ្គល។ ប៉ុន្តែរាល់ទំនាក់ទំនងក្នុងសង្គម តែងតែជៀសមិនផុតពីជំលោះឡើយ តែជំលោះខ្លះត្រូវបានផ្សះផ្សាគ្នាក៏រលត់បាត់ទៅ តែជំលោះខ្លះមិនអាចផ្សះផ្សាបានដោយភាគីទាំងពីរ មិនទទួលយកការសម្របសម្រួលនោះ ហើយឈានទៅដល់ការប្តឹងផ្តល់គ្នានៅតុលាការ ប៉ុន្តែការដាក់បណ្តឹងក៏មិនមែនចេះតែដាក់នោះទេ គឺត្រូវរកតុលាការណាដែលមានសមត្ថកិច្ច។ ក្នុងក្រមរដ្ឋប្បវេណីមានមាត្រាជាច្រើន ដែលចែងពីសមត្ថកិច្ចតុលាការ ប៉ុន្តែសមត្ថកិច្ចទាំងនោះសមត្ថកិច្ចត្រូវយកមកអនុវត្តដំបូងគេដែលឲ្យឈ្មោះថាសមត្ថកិច្ចចំបង (១) ហើយបើភាគីនៃបណ្តឹងមិនអាចអនុវត្តសមត្ថកិច្ចចំបងបាន ទើបពិចារណាអំពីសមត្ថកិច្ចផ្សេងៗទៀត (២)។

## ១. សមត្ថកិច្ចចំបង

ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី សមត្ថកិច្ចតុលាការត្រូវពិចារណាដំបូងគេ គឺសមត្ថកិច្ចតាមលំនៅដ្ឋានរបស់ចុងចម្លើយ (១.១) ប៉ុន្តែបើរឿងក្តីទាក់ទងទៅនឹងសមត្ថកិច្ចផ្តាច់មុខ (១.២) ករណីនេះយើងត្រូវមកអនុវត្តតាមសមត្ថកិច្ចផ្តាច់មុខវិញ។

### ១.១ សមត្ថកិច្ចលំនៅដ្ឋានរបស់ចុងចម្លើយ

នៅក្នុងនីតិរដ្ឋប្បវេណី បានបែងចែកបុគ្គលជា រូបវន្តបុគ្គល (បុគ្គលម្នាក់ៗ) និងនីតិបុគ្គល (ក្រុមមនុស្សដែលមានបទដ្ឋានគតិយុត្ត មានដូចជា ក្រុមហ៊ុន សមាគម ឬ ស្ថាប័ន ជាដើម)[1]។

[1] មាត្រា ៨៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

❖ **សមត្ថកិច្ចរបស់រូបបុគ្គលៈ** តុលាការដែលមានសមត្ថកិច្ច គឺនៅលំនៅដ្ឋានរបស់ចុងចម្លើយ[2]។ ឧទាហរណ៍ លោក ក លំនៅដ្ឋាននៅភ្នំពេញដែលគាត់មានបំណងចង់ប្តឹងលោក ខ រស់នៅក្នុងខេត្តកណ្តាល។ ករណីនេះ តុលាការដែលមានសមត្ថកិច្ចគឺ តុលាការខេត្តកណ្តាល (លំនៅដ្ឋានរបស់ចុងចម្លើយ)។

ប៉ុន្តែប្រសិនបើករណីដើមបណ្តឹង មិនបានដឹងពីលំនៅដ្ឋាន ពិតប្រាកដរបស់ចុងចម្លើយ នោះដើមបណ្តឹងអាចប្តឹងទៅតុលាការ ដែលជាទីសំណាក់ចុងក្រោយរបស់ចុងចម្លើយបាន។ ឧទាហរណ៍ ករណីលោក ក មិនបានស្គាល់ពីផ្ទះរបស់លោក ខ ទេ តែដឹងត្រឹមតែលោក ខ បានជួលផ្ទះគេរស់នៅភ្នំពេញ ករណីនេះតុលាការដែលមានសមត្ថកិច្ចគឺ តុលាការភ្នំពេញ។ ករណីមួយទៀត បើដើមបណ្តឹងមិនស្គាល់ទាំងលំនៅដ្ឋាន និងទីសំណាក់ ដើមបណ្តឹងអាចប្តឹងទៅលំនៅដ្ឋានចុងចម្លើយ ថានៅទីណាពិតប្រាកដ។ ឧទាហរណ៍ លោក ក មិនបាននៅផ្ទះ ឬ ផ្ទះជួលរបស់លោក ក ប៉ុន្តែបានជួបលោក ក ចុងក្រោយបង្អស់នៅខេត្តបាត់ដំបង។ ករណីនេះ តុលាការដែលលោក ក ជួបលោក ខ ចុងក្រោយនោះតុលាការដែលមានសមត្ថកិច្ច គឺតុលាការបាត់ដំបង។

❖ **សមត្ថកិច្ចតុលាការរបស់នីតិបុគ្គលៈ** សមត្ថកិច្ចនីតិបុគ្គលនេះ គឺសំដៅតែទៅលើចុងចម្លើយតែប៉ុណ្ណោះ។ ឧទាហរណ៍ លោក ក បានប្តឹងក្រុមហ៊ុន AZ ទៅតុលាការ។ ករណីនេះពេលដែលប្តឹងទៅតុលាការ គឺជាសមត្ថកិច្ចរបស់នីតិបុគ្គល ប៉ុន្តែបើក្រុមហ៊ុនប្តឹងលោក ក វិញ គឺមិនមែនជាសមត្ថកិច្ចតុលាការ របស់ចុងចម្លើយទេ។ សរុបជារួមភាគីចុងចម្លើយជានីតិបុគ្គល ចំណែកដើមបណ្តឹងជារូបវន្តបុគ្គល ឬនីតិបុគ្គល គឺយើងមិនពិចារណាទេ។ ក្នុងសមត្ថកិច្ចតុលាការរបស់នីតិបុគ្គល គឺបែងចែកជាពីរគឺ នីតិបុគ្គលក្នុងប្រទេស និងនីតិបុគ្គលបរទេស។

➢ នីតិបុគ្គលក្នុងប្រទេសៈ សមត្ថកិច្ចតុលាការស្ថិតនៅទីតាំង នៃទីស្នាក់ការ ឬកន្លែងអាជីវកម្មជាចម្បង[3]។ ឧទាហរណ៍ ក្រុមហ៊ុន AZ មានទីស្នាក់ការស្ថិតនៅខេត្តកំពង់ចាម ត្រូវ

---

[2] មាត្រា ៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[3] មាត្រា ៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

លោក សីហា ប្តឹងទាមទារប្រាក់ ដែលលោក សីហា រស់នៅភ្នំពេញ។ ករណីនេះ តុលាការកំពង់ចាម (ទីស្នាក់ការរបស់នីតិបុគ្គល) ជាតុលាការដែលមានសមត្ថកិច្ច។

សមត្ថកិច្ចតុលាការ អាចជាលំនៅដ្ឋានរបស់អ្នកតំណាង ឬរបស់អ្នកទទួលខុសត្រូវភារកិច្ចចាត់ចែងការងារជាចម្បង បើគ្មានទីស្នាក់ ឬ ទីតាំងអាជីវកម្ម។

- **នីតិបុគ្គលបរទេស៖** សមត្ថកិច្ចតុលាការ ស្ថិតនៅទីស្នាក់ការ ឬទីកន្លែងអាជីវកម្មជាចម្បង។ ត្រង់ចំណុចនេះ សូមបញ្ជាក់ថា នីតិបុគ្គលបរទេស គឺជានីតិបុគ្គលដែលមានសញ្ជាតិបរទេស នីតិបុគ្គលនោះមានភាគហ៊ុនបរទេសកាន់កាប់ ៥១% ឡើងទៅ[4]។ ឧទាហរណ៍ ក្រុមហ៊ុន A ជាក្រុមហ៊ុនស្ថិត នៅប្រទេសចិនហើយមានទីស្នាក់ការធំនៅទីនោះ ក្រុមហ៊ុននេះមានសាខានៅក្នុងប្រទេសកម្ពុជាស្ថិតនៅក្នុងខេត្តកំពត។ លោក ក រស់នៅក្នុងខេត្តតាកែវបានប្តឹងក្រុមហ៊ុន A ករណីនេះតុលាការដែលមានសមត្ថកិច្ច គឺតុលាការខេត្តកំពត។

ប៉ុន្តែបើនីតិបុគ្គបរទេស មិនមានទីស្នាក់ការនៅក្នុងប្រទេសកម្ពុជាទេ លំនៅដ្ឋានរបស់អ្នកតំណាងប្រចាំនៅកម្ពុជា ឬរបស់អ្នកទទួលខុសត្រូវ ភារកិច្ចចាត់ចែងការងារចម្បងក្នុងព្រះរាជាណាចក្រកម្ពុជា។ ឧទាហរណ៍ លោក **ក** ជាអ្នកតំណាងឲ្យអង្គការបរទេសក្នុងប្រទេសកម្ពុជា ពេលដែលមកបំពេញការងារនៅកម្ពុជា គាត់បានរស់ភ្នំពេញ ដូច្នេះបើមានបុគ្គលណាម្នាក់ប្តឹងអង្គការបរទេសនោះ តុលាការដែលមានសមត្ថកិច្ច គឺតុលាការភ្នំពេញ។

## ១.២ សមត្ថកិច្ចផ្តាច់មុខ

សមត្ថកិច្ចផ្តាច់មុខមានចែងក្នុងមាត្រា ១០ និង មាត្រា ១៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី និងច្បាប់ទាក់ទងនឹងឋានៈបុគ្គល។ សមត្ថកិច្ចផ្តាច់មុខមានដូចជារឿងក្តីលែងលះ និង បណ្តឹងទាមទារបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃបុគ្គភាព ដែលត្រូវស្ថិតនៅសមត្ថកិច្ចផ្តាច់មុខ នៃសាលាដំបូងលំនៅដ្ឋានរបស់ភាគីនៃទំនាក់ទំនងឋានៈបុគ្គល ដែលពាក់ពន្ធ័នឹងបណ្តឹងនោះ ឬលំនៅដ្ឋាននាពេលដែលភាគី

[4] មាត្រា ២៨៣ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥។

នោះទទួលមរណភាព[5]។ ឧទាហរណ៍ លោក ណារិន រស់នៅភ្នំពេញលោកមានបំណងប្ដឹងបញ្ជាក់អំពីនត្ថិភាពនៃបុគ្គភាព ករណីនេះលោក ណារិន អាចប្ដឹងទៅតុលាការភ្នំពេញ ឬលោកអាចប្ដឹងទៅតុលាការដែលជាលំនៅដ្ឋានបុគ្គភាពដែលលោកចង់បញ្ជាក់ក៏បាន (លំនៅដ្ឋានចុងចម្លើយក៏បាន)។

ករណីដែលបើភាគីមិនមានលំនៅដ្ឋាន ក្នុងព្រះរាជាណាចក្រកម្ពុជា ឬលំនៅដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាមិនពិតប្រាកដទេ សមត្ថកិច្ចសាលាជម្រះក្ដីត្រូវកំណត់តាមទីសំណាក់។ បើពុំមានទីសំណាក់ ឬទីសំណាក់មិនពិតប្រាកដ សមត្ថកិច្ចនោះត្រូវកំណត់តាមលំនៅដ្ឋានចុងក្រោយ[6]។ ទោះបីជាមានសមត្ថកិច្ចតាមលំនៅដ្ឋាន របស់ចុងចម្លើយក៏ដោយ សមត្ថកិច្ចផ្ដាច់មុខត្រូវយកមកអនុវត្ត។ម្យ៉ាងទៀតសមត្ថកិច្ចផ្ដាច់មុខ ភាគីមិនអាចព្រមព្រៀងយកតុលាការណាមួយផ្សេង ដែលមិនមែនជាលំនៅដ្ឋាន ឬទីសំណាក់ ឬ លំនៅដ្ឋានចុងក្រោយបានឡើយ។ ទោះបីជាភាគីដាក់ពាក្យបណ្ដឹងខុសសមត្ថកិច្ចតុលាការ ហើយគ្មានការតវ៉ាពីចុងចម្លើយក៏ដោយក៏តុលាការនោះ មិនអាចក្លាយជាតុលាការមានសមត្ថកិច្ចបានដែរ[7]។

## ២. សមត្ថកិច្ចផ្សេងៗ

ការកំណត់សមត្ថកិច្ចដែលបានលើកឡើងខាងលើ គឺជាសមត្ថកិច្ចទូទៅ និង ផ្ដាច់មុខដើម្បីជួយសម្រួលដល់គូភាគីធ្វើការពិចារណា ក្នុងការដាក់ពាក្យបណ្ដឹងរបស់ខ្លួន ទៅតុលាការដែលមានសមត្ថកិច្ច ប៉ុន្តែក្រៅពីសមត្ថកិច្ចទាំងនោះ ក៏នៅមានសមត្ថកិច្ចផ្សេងៗទៀតដូចជា សមត្ថកិច្ចតាមទ្រព្យសម្បត្តិ (២.១) និង សមត្ថកិច្ចដែលកំណត់ដោយតុលាការជាន់ខ្ពស់ (២.២)។

### ២.១ សមត្ថកិច្ចតាមទ្រព្យសម្បត្តិ

ក្រៅពីតុលាការដែលបានបកស្រាយក្នុងចំណុច (១) ខាងលើនេះ សមត្ថកិច្ចតុលាការផ្អែកទៅតាមពាក្យបណ្ដឹងនៅទីកន្លែងដែលបានកំណត់ក្នុងចំណុចនីមួយៗដូចខាងក្រោម[8]៖

---

[5] មាត្រា ៣ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០។
[6] មាត្រា ៥ កថាខណ្ឌទី២ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០។
[7] មាត្រា ១៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[8] មាត្រា ៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

❖ **បណ្តឹងទាមទារឲ្យអនុវត្តកាតព្វកិច្ច៖** កន្លែងដែលត្រូវអនុវត្តកាតព្វកិច្ច។ ឧទាហរណ៍៖ លោក ក ធ្វើកិច្ចសន្យាប្រគល់បន្លែនៅផ្សារដើមគ ទៅឲ្យលោក ខ ករណីនេះបើសិនជាជំលោះកើតឡើង តុលាការភ្នំពេញជាតុលាការមានសមត្ថកិច្ច។

❖ **បណ្តឹងទាមទារឲ្យបង់ប្រាក់ដោយរូបិយាណត្តិ ឬមូលប្បទាប័ត្រ៖** កន្លែងបង់រូបិយាណត្តិ ឬ មូលប្បទានប័ត្រ។

❖ **បណ្តឹងទាមទារឲ្យអនុវត្តកាតព្វកិច្ច ចំពោះបុគ្គលដែលពុំមានលំនៅដ្ឋានក្នុងព្រះរាជាណាចក្រកម្ពុជា ឬលំនៅដ្ឋានមិនពិតប្រាកដ៖** កន្លែងដែលជាកម្មវត្ថុនៃការទាមទារ ឬកម្មវត្ថុនៃប្រាតិភោគដែលធានាលើការទាមទារនោះ ឬទ្រព្យរបស់ចុងចម្លើយដែលអាចរឹបអូសបានស្ថិតនៅ។

❖ **បណ្តឹងទាមទារឲ្យអនុវត្តកាតព្វកិច្ចចំពោះនីតិបុគ្គលដែលពុំមានទីស្នាក់ការ ឬកន្លែងអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ឬទីស្នាក់ការ ឬកន្លែងទីអាជីវកម្មមិនពិតប្រាកដ៖** កន្លែងដែលកម្មវត្ថុនៃការទាមទារ ឬកម្មវត្ថុនៃប្រាតិភោគដែលធានាលើការទាមទារ ឬទ្រព្យរបស់ចុងចម្លើយស្ថិតនៅ។

❖ **បណ្តឹងចំពោះបុគ្គលដែលមានទីស្នាក់ការ ឬទីកន្លែងអាជីវកម្មដែលទាក់ទងនឹងសកម្មភាពការងាររបស់ទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មនោះ៖** ទីតាំងនៃទីស្នាក់ការ ឬទីកន្លែងអាជីវកម្មនោះ។

❖ **បណ្តឹងទាក់ទងនឹងអនីត្យានុកូល៖** កន្លែងដែលអំពើអត្យានុកូលកើតឡើង។ លោក ក បើកឡានគៀរ លោក សីហា នៅភ្នំពេញ។ ដូច្នេះតុលាការភ្នំពេញជាតុលាការមានសមត្ថកិច្ច។

❖ **បណ្តឹងទាក់ទងនឹងអចលនវត្ថុ៖** កន្លែងដែលអចលនវត្ថុនោះស្ថិតនៅ។ លោក **ក** បានប្តឹងទាមទារដីពីលោក ខ ដែលដីនោះស្ថិតនៅខេត្តបាត់ដំបង ករណីនេះតុលាការខេត្តបាត់ដំបងជាតុលាការមានសមត្ថិកច្ច។

❖ **បណ្តឹងទាក់ទងនឹងការចុះបញ្ជី៖** កន្លែងដែលត្រូវចុះបញ្ជី។ ក្រុមហ៊ុន ក បានចុះបញ្ជីពន្ធដារនៅក្នុងខេត្តកណ្តាល ករណីតុលាការខេត្តកណ្តាលជាតុលាការមានសមត្ថកិច្ចពេលមានវិវាទ។

❖ **បណ្តឹងទាក់ទងមតក៖** លំនៅដ្ឋានមតកជន នៅពេលសន្តតិកម្ម ត្រូវចាប់ផ្តើម ឬទីសំណាក់ បើមតកជនពុំមានលំនៅដ្ឋានក្នុងព្រះរាជាណាចក្រកម្ពុជា ឬមានលំនៅដ្ឋានមិនពិតប្រាកដ ឬ លំនៅដ្ឋានចុងក្រោយ បើមតកជននោះពុំមានទីសំណាក់ក្នុងព្រះរាជាណាចក្រកម្ពុជា ឬ មានទីសំណាក់មិនពិតប្រាកដ។

ករណីដែលបណ្តឹងទាមទារច្រើនចំណុច ដែលស្ថិតនៅសាលាជម្រះក្តីផ្សេងគ្នា ដើមបណ្តឹងអាចប្តឹងទៅតុលាការដែលមានសមត្ថកិច្ចណាមួយក៏បានដែរ ដោយបញ្ចូលការទាមទារផ្សេងទៀតបញ្ចូលគ្នា[9]។ ឧទាហរណ៍ លោក ទឹកដោះគោ មានជំលោះជាមួយលោក នំប៉័ង រឿងដីធ្លីស្ថិតនៅក្នុងខេត្តកំពង់ចាមមួយកន្លែង និងជំលោះទាមទារផ្ទះវីឡាមួយនៅភ្នំពេញ។ ករណីនេះលោក ទឹកដោះគោ អាចជ្រើសរើសតុលាការខេត្តកំពង់ចាម ឬ តុលាការតុលាការភ្នំពេញ ដែលជាតុលាការមានសមត្ថកិច្ចដោយបញ្ចូលរឿងក្តីនៅកំពង់ចាម និងនៅភ្នំពេញបញ្ចូលទៅក្នុងបណ្តឹងតែមួយតែម្តង។ ភាគីក៏អាចព្រមព្រៀង អំពីការកំណត់សម្តកិច្ចតុលាការបានដែរ ប៉ុន្តែបានតែរឿងពាណិជ្ជកម្ម នៅក្នុងការជំនុំជម្រះលើកទី១ (សាលាដំបូង)[10] ហើយការព្រមព្រៀងត្រូវសសេរជាលាយលក្ខខណ្ឌអក្សរ[11]។ ករណីដើមបណ្តឹង ដាក់ពាក្យបណ្តឹងខុសសមត្ថកិច្ច ប៉ុន្តែមិនមានការតវ៉ាពីចុងចម្លើយទេតុលាការដែលដើមចោទដាក់ពាក្យបណ្តឹងនោះ អាចចាត់ការលើបណ្តឹងនោះបាន[12]។

## ២.២ សមត្ថកិច្ចដែលកំណត់ដោយតុលាការជាន់ខ្ពស់

ក្នុងករណីដែលតុលាការមានសមត្ថកិច្ច មិនអាចអនុវត្តនូវសិទ្ធិជម្រះក្តី បានដោយសារច្បាប់ (ឧទាហរណ៍ ការប្តឹងជិតចិត្តចៅក្រមរហូតដល់អស់ចៅក្រមពីតុលាការ ដូច្នេះត្រូវរកតុលាការផ្សេង

[9] មាត្រា ១១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[10] មាត្រា ១៣ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[11] មាត្រា ១៣ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[12] មាត្រា ១៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

មកជំនួស) ឬ ហេតុការណ៍ពិត (ប្រធានសក្តិ) ឬករណីដែលសមត្ថកិច្ចសាលាជម្រះក្តីមិនពិតប្រាកដ តុលាការកំពូលត្រូវកំណត់តុលាការដែលមានសមត្ថកិច្ច ដោយដីកាសម្រេចតាមពាក្យសុំ[13]។

តុលាការអាចផ្ទេរបណ្តឹងទាំងមូល ឬផ្នែកណាមួយដែលមិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួនទេ តុលាការនេះត្រូវផ្ទេរបណ្តឹងនោះទៅតុលាការណាដែលមានសមត្ថកិច្ចតាមពាក្យសុំរបស់ភាគី ឬតាមឆន្ទានុសិទ្ធិរបស់ខ្លួន[14]។ ពាក្យសុំត្រូវសសេរជាលាយលក្ខណ៍អក្សរ លើកលែងតែពាក្យសុំនៅកាលបរិច្ឆេទ[15] ហើយនៅពេលធ្វើពាក្យសុំ ត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់អំពីពាក្យសុំនោះ។ តុលាការក៏អាចផ្ទេរសម្ថកិច្ចបានដោយឆន្ទានុសិទ្ធិ ឬតាមការស្នើសុំ ដើម្បីជៀសវាងពីការយឺតយ៉ាវ ទោះបីជាបណ្តឹងស្ថិតនៅសមត្ថកិច្ចរបស់ខ្លួនក៏ដោយ[16]។ ប៉ុន្តែតុលាការត្រូវសួរយោបល់ ពីភាគីម្ខាងទៀតផងដែរ[17]។

## សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមកឃើញថា សមត្ថកិច្ចតុលាការពិតជាស្មុគស្មាញ ដូច្នេះដើមបណ្តឹងមុននឹងសម្រេចចិត្តដាក់ពាក្យបណ្តឹង ទៅតុលាការត្រូវតែយល់ពីតុលាការណាមួយ ដែលមានសមត្ថកិច្ច ពីព្រោះការជ្រើសរើស តុលាការដែលមានសមត្ថកិច្ច គឺជាការផ្តល់នូវផលចំណេញមួយសម្រាប់គូភាគីចំណេញទាំងពេលវេលា និង ប្រាក់កាស។

[13] មាត្រា ១២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[14] មាត្រា ១៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[15] មាត្រា ១៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[16] មាត្រា ១៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[17] មាត្រា ១៩ កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

# ឯកសារពិគ្រោះ

- ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
- ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
- ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥។
- ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០។